# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

## រវាងតំណាងសហជីពកម្មករកម្ពុជានិងតំណាងកម្មករប្រចាំរោងចក្រជាមួយក្រុមហ៊ុនស៊ីភីស៊ីជី

ឆ្នាំ២០២៣ ខែ សីហា ថ្ងៃទី ១៨ វេលាម៉ោង២រសៀល នៅក្នុងការិយាល័យក្រុមហ៊ុនស៊ីភីស៊ីជី ដែលមានទីតាំងស្ថិតនៅភូមិឈូក ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្ត កំពង់ចាម ។មានកិច្ចប្រជុំពិភាក្សាអំពីរដំណើរការសុំព្យួរការងារកម្មករនិយោជិតនៅថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២៣។

### ខ្លឹមសារនៃកិច្ចព្រមព្រៀង

ដោយសារកង្វះការបញ្ជាទិញរបស់រោងចក្រនាពេលបច្ចុប្បន្ន រោងចក្រជាច្រើនកំពុងប្រឈមនឹងហានិភ័យនៃការគ្មានការបញ្ជាទិញរបស់អតិថិជន។ដូច្នេះក្រុមហ៊ុនស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិកចំនួន ៥៩៧នាក់ (ស្រី ៥៦០នាក់)ក្នុងចំណោមកម្មករនិយោជិកសរុបចំនួន ១៣៧៦ (ស្រី ១២៨៤នាក់) ។ ដោយយោងតាមឯកសារផ្លូវការលេខ 020/23 សេចក្តីណែនាំរបស់រដ្ឋាភិបាលនិងដើម្បីធានានូវស្ថិរភាពអាជីវកម្មរបស់រោងចក្រ នាយករោងចក្របានធ្វើការពិភាក្សាជាមួយបងប្អូនតំណាងសហជីព,តំណាងកម្មករនិងប្រធានក្រុមការងារនៃរោងចក្រទាំងមូលដើម្បីកំណត់ការផ្លាស់វេនគ្នាព្យួរកិច្ចសន្យាការងាររបស់បងប្អូនកម្មករនិយោជិក។ ក្រោយពេលពិភាក្សាគ្នារួចមកភាគីរោងចក្រនិងភាគីតំណាងកម្មករបានឯកភាពគ្នាដូចតទៅៈ

**ចំណុចទី១**: ក្រុមហ៊ុនបានរៀបចំអោយបងប្អូនសំរាកចំនួន២ខែ។

- ចាប់ផ្តើមអោយសំរាកពីថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣( ២ខែ )
- បើកប្រាក់ឧបត្ថម្ភព្យួរការងារក្រុមហ៊ុនផ្តល់ជូនបងប្អូនកម្មករនិយោជិក៣០ដុល្លាក្នុង១ខែ។
- ថ្ងៃទី ៣១ ខែ សីហា ក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភមុនថ្ងៃព្យួរ១ថ្ងៃ
- សំរាប់កម្មករព្យួរការងារទាំងអស់សំរាប់ប្រាក់ខែ ខែ៨គឺបើកនៅថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០២៣ខាងមុខ។

**ចំណុចទី២**: ក្នុងកំឡុងពេលព្យួរបើក្រុមហ៊ុនមានឥវ៉ាន់ធ្វើមុនការកំណត់រយៈពេលព្យួរ ពេលនោះប្រាក់សំរាប់រយៈពេលព្យួរដែលនៅសល់ក្រុមហ៊ុននឹងធ្វើការកាត់កងតាមចំនួនថ្ងៃដែលបានធ្វើការ។

កិច្ចប្រជុំពិភាក្សានេះត្រូវបានចប់សព្វគ្រប់វេលាម៉ោង៣រសៀលនៅថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសរីករាយនិងយោគយល់គ្នា។

**សមាសភាពចូលរួមមានៈ** ( **មានបញ្ជីអវត្តមានភ្ជាប់ជូន** )

| | | |
|---|---|---|
| តំណាងរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី : | លោក ឈើនមីន ស្យុង | ប្រធានគ្រប់គ្រងរោងចក្រ |
| តំណាងរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី : | លោកស្រី សេង អ៊ី ឆេង | អ្នកបកប្រែ |
| តំណាងសហជីបប្រចាំរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី: | លោកស្រី ខូវ និមល | ប្រធានសហជីព |
| តំណាងសហជីបប្រចាំរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី: | លោកស្រី ធូ គីមស្រ៊ួន | អនុប្រធានសហជីព |
| តំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី ខូអិលធីឌី: | លោកស្រី យឿន សារីម | តំណាងកម្មករ |
| តំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី ខូអិលធីឌី: | លោកស្រី យន់ ចារី | តំណាងកម្មករ |

និងមានតំណាងសហជីព,តំណាងកម្មករនិងប្រធានក្រុម ប្រធានផ្នែកផ្សេងទៀតចូលរួមដែលមានរាយឈ្មោះដូចខាងក្រោមៈ

តំណាងសហជីបនិងតំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី

ខូវ និមល :

ធូ គីមស្រ៊ួន :

យឿន សារីម :

យន់ ចារី :

ឆាត អ៊ីស៊ាន :

យាន លាង :

ណាំ សាយ៉ន :

តំណាងក្រុមហ៊ុនស៊ីភីស៊ីជី

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ីភីស៊ីជី អ៊ិនធើណេសិនណល CPCG INTERNATIONAL CO.,LTD. KINGDOM OF CAMBODIA

ឈើនមីន ស្យុង

សេង អ៊ី ឆេង (អ្នកបកប្រែ)